**ទុក្ខា**

**"នេះគឺជារឿងរ៉ាវរបស់និស្សិតម្នាក់ដែលធ្លាប់ស្រមៃចង់បានពិភពលោកមួយដែលប្រសើរជាងមុន "**

**ទុក្ខា**

មើលនោះន៎..! អ្នកណាកំពុងដើរមកនេះ?

នេះគឺជាអ្នកស្រីសារុន គាត់គឺជាគ្រូបង្រៀន។

គាត់មានអាយុ ៥២ឆ្នាំ ។

គាត់តែងតែទៅឈរយ៉ាងស្ងៀមស្ងាត់តែម្នាក់ឯងនៅឯផ្សារ ជារៀងរាល់ចុងសប្តាហ៍។

គាត់ទៅតែម្នាក់ឯងគត់។

សូមយើងទាំងអស់គ្នាស្តាប់រឿងរ៉ាវរបស់គាត់។

**និស្សិត**

ខ្ញុំឈ្មោះសារុន ខ្ញុំរស់នៅតែម្នាក់ឯងប៉ុណ្ណោះ។ កាលពីតូចខ្ញុំគឺជាសិស្សល្អម្នាក់នៅឯសាលារៀនក្នុងភូមិនេះ ។ ឪពុកម្តាយខ្ញុំមានមោទនភាពចំពោះខ្ញុំខ្លាំងណាស់ ។ ពុកខ្ញុំខិតខំធ្វើការ ដើម្បីអោយខ្ញុំអាចទៅរៀនសូត្រក្នុងសាកលវិទ្យាល័យនៅភ្នំពេញ។ គាត់តែងស្រម៉ៃថាខ្ញុំនឹងអាចក្លាយជាសាស្ត្រាចារ្យម្នាក់។

កាលណោះគឺជាជំនាន់ **លន់ ណុល**ហើយស្ថានភាពមិនល្អទាល់តែសោះ។ នៅក្នុងប្រទេសមានភាពវឹកវរសម្បើមណាស់ ។

និស្សិតដូចពួកខ្ញុំគឺជាអ្នកដែលមានការស្រមើស្រម៉ៃវែង

| | |
|---|---|
| ឆ្ងាយ ។ យើងចង់បានសង្គមមួយ និងពិភពមួយដែលល្អជាងនេះ ។យើងក៏បានធ្វើបាតុកម្មដ៏ធំមួយប្រឆាំងរដ្ឋាភិបាល ហើយពួកនិស្សិតជាច្រើននាក់ក៏ត្រូវបានគេចាប់ខ្លួន រួមទាំងរូបខ្ញុំផង។ | |
| នៅក្នុងគុកគេធ្វើទារុណកម្មខ្ញុំខ្លាំងណាស់។ គេវាយធ្វើបាបខ្ញុំ ហើយថែមទាំងឆក់ខ្សែភ្លើងខ្ញុំទៀតផង។ ប៉ុន្តែការដែលគេធ្វើបែបនេះ គឺធ្វើអោយខ្ញុំស្អប់ **លន់ ណុល** កាន់តែខ្លាំងឡើង។ នៅពេលដែលគេដោះលែងខ្ញុំ ខ្ញុំក៏រត់ចូលព្រៃ គឺពេលនោះហើយដែលខ្ញុំបានជួបជាមួយខ្មែរក្រហម។ ខ្មែរក្រហមធ្វើការប្រយុទ្ធដើម្បីទទួលបាននូវសង្គមមួយដែលប្រសើរជាងនេះ គឺប្រទេសមួយដែលពោរពេញទៅដោយសេរីភាព...គ្មានអំពើរពុករលួយ ហើយគ្រប់គ្នាមានអាហារហូបចុកគ្រប់គ្រាន់ ។ ខ្ញុំពិតជាជឿជាក់អញ្ចឹងមែន ។<br>ដូច្នេះខ្ញុំក៏ចង់ចូលរួមជាមួយគេឯងដ៏ទៃទៀត ។<br>ខ្ញុំយល់ថា ខ្ញុំមិនអាចបង្ហាញអោយគេដឹងថាខ្ញុំជាអ្នកដែលរៀនសូត្របានខ្ពស់នោះទេ ។ ខ្ញុំខំធ្វើការដើម្បីអោយដៃខ្ញុំឡើងគ្រើមនិងហាលថ្ងៃដើម្បីអោយសម្បុរខ្ញុំខ្មៅដូចអ្នកស្រែចំការ។<br>ខ្ញុំខំដាក់ខ្លួនធ្វើការអោយបានល្អ ។ នៅទីបញ្ចប់ខ្ញុំធ្វើអ្វីៗគ្រប់យ៉ាងតាមតែគេចង់បាន ។ ខ្ញុំពួននៅក្រោមផ្ទះគេ ដើម្បីលួចស្តាប់គេនិយាយគ្នា។ ខ្ញុំចាប់មនុស្ស។ ខ្ញុំធ្វើរឿងអាក្រក់និងសាហាវជាច្រើន។ ខ្ញុំលែងគិតដូច | **អ្នកសន្យាថានឹងផ្តល់អោយយើងនូវឋានសួគ៌ តែយើងទទួលបានត្រឹមតែនរកទៅវិញ។**<br><br>**ហេតុអី.......ហេតុអី............ហេតុអី?**<br><br>**វីក៏**<br><br>**ឱ..ព្រះជាម្ចាស់ហើយ...**<br>**ហេតុអ្វីបានជាប្រទេសកម្ពុជាទៅវិញ...?** |

| | |
|---|---|
| មនុស្សទៀតហើយ..ខ្ញុំប្រៀបដូចជា សត្វឆ្កែមួយក្បាល គឺចាំតែមើលមុខចៅហ្វាយនាយ និងបក់កន្ទុយដោយខ្លាចគេវ៉ាយ ។ | |
| | ចំរៀង បទ “ វិនាសវប្បធម៏ “<br>និពន្ធដោយលោក សំអ៊ូ អឿ ថត<br>អស់ជាមនុស្សទៀតហើយ<br>ពីពេលនេះទៅគ្មានយប់ថ្ងៃទេ<br>ឆ្លងវាលអវីចីសែនអនិច្ចា<br>មិនដឹងយ៉ាងណា ណាព្រះអើយ..។<br>រីក៏ Cambodian People’s Lament |
| បន្ទាប់ពីបដិវត្តន៍ចប់ខ្ញុំបានត្រលប់ទៅកាន់ស្រុកកំនើតខ្ញុំវិញ ។ ឥឡូវនេះខ្ញុំរស់នៅដោយខ្លួនឯង ។ ខ្ញុំបង្រៀននៅឯសាលាបឋមសិក្សាដែលខ្ញុំធ្លាប់រៀនកាលពីមុន ។ ខ្ញុំលឺគេថាខ្មែរក្រហមសម្លាប់ឪពុកខ្ញុំនៅពេលដែលគាត់កំពុងធ្វើការនៅវាលស្រែ ពុកដ៏ស្លូតបូតរបស់ខ្ញុំដែលធ្លាប់តែស្រមៃថាខ្ញុំនឹងក្លាយទៅជាសាស្ត្រាចារ្យម្នាក់។ គេវាយគាត់រហូតដល់ស្លាប់ ដោយសារតែគាត់ខ្សោយពេកគ្មានកម្លាំងធ្វើការ ។ | |
| ជួនកាលខ្ញុំខឹង ហើយជួនកាលខ្ញុំក្រៀមក្រំ។ ក្នុងក្បាលរបស់ខ្ញុំពោរពេញដោយភាពរញ៉េរញ៉ៃ។<br>ខ្ញុំមិនយល់ តើប្រទេសទាំងមូលត្រូវបានគេបោកបញ្ឆោតយ៉ាងដូចម្តេចទៅ ?តើខ្ញុំត្រូវបានគេបោកបញ្ឆោតយ៉ាងដូចម្តេចទៅ ? | |

| | |
|---|---|
| ត្រូវហើយខ្ញុំបន្ទោសខ្មែរក្រហមសំរាប់ការដែលគេនាំខ្ញុំអោយដើរផ្លូវខុស ប៉ុន្តែវាក៏ជាកម្មរបស់ខ្ញុំដែរ ដូច្នេះខ្ញុំមិនអាចធ្វើអ្វីបានឡើយ ក្រៅពីបន្ទោសខ្លួនឯង ។<br><br>ខ្ញុំទៅផ្សារ ហើយឃើញម៉ែខ្ញុំ។ គាត់អត់មានរាក់ទាក់ដាក់ខ្ញុំទេ។ គាត់បែរជាឈ្ងោកមុខ ហើយដើរចេញ ។ ខ្ញុំចង់ប្រាប់គាត់ថា ខ្ញុំត្រូវការគាត់ ។<br><br>**ទុត្ថា**<br>នេះគឺជាម្តាយរបស់សារុន ។ គាត់មានអាយុ ៧៥ឆ្នាំ ។ គាត់បាត់បង់ការស្រលាញ់ពីកូន ។<br><br>**ធារី**<br>ខ្ញុំទៅផ្សារ ។ អោយតែដឹងថាកូនខ្ញុំនៅផ្សារ ខ្ញុំតែងតែទៅរកគេជានិច្ច ។ ប៉ុន្តែនៅពេលដែលកូនសម្លឹងមើលមកខ្ញុំ ខ្ញុំមិនអាចសម្លឹងមើលទៅកាន់កូនវិញទេហើយខ្ញុំក៏ដើរចេញទៅ ។ ខ្ញុំខ្មាសគេដែលមានកូនបែបនេះ ។ ប្តីរបស់ខ្ញុំត្រូវគេវ៉ាយរបស់ដល់ស្លាប់ ហើយខ្ញុំថែមទាំងបាត់បង់កូនទៀតនៅពេលដែលកូនខ្ញុំបានក្លាយទៅជាពេជ្ឈឃាតម្នាក់ ។<br>ខ្ញុំលឺថា ឥឡូវនេះកូនខ្ញុំជាគ្រូបង្រៀនដ៏ល្អម្នាក់ គេមិនដែលវ៉ាយក្មេងៗ ហើយតែងតែអត់ធ្មត់ពន្យល់ក្មេងជានិច្ច នៅពេលដែលលឺដំណឹងនេះខ្ញុំក៏ល្មួចមានមោទនភាពចំពោះកូនខ្ញុំដែរ ។ | **សំលេងគង**<br><br>**ហេតុអី.......ហេតុអី............ហេតុអី?**<br>**តើហេតុអីបានជាមានដង្កូវចេញពីសាច់ដូច្នេះ?** |

នៅពេលដែលកូនសម្លឹងមើលមកខ្ញុំរាល់ពេលដែលវាទៅផ្សារ ខ្ញុំដឹងថាវាចង់អោយខ្ញុំអត់ទោសអោយវា ប៉ុន្តែពិបាកណាស់។

**ស៊ីណា**

ម្តាយ និងកូននៅឈរស្ងៀមមួយកន្លែង ។
នៅស្ងៀមទ្រឹងមួយស្របក់ ។
បន្ទាប់មក កូនក៏ដើរសំដៅទៅរកម្តាយហើយគាត់ឱននិយាយថា……

**និស្សិត**

ម៉ែ…អត់ទោសអោយខ្ញុំផង…ខ្ញុំបានធ្វើអំពើរអាក្រក់.. អោយខ្ញុំសូមទោស។ តើធ្វើម៉េចទៅទើបខ្ញុំអាចលាងបាបនេះបាន ?

**សង់ស្ពានវាប្រសើរជាងធ្វើជញ្ជាំង។**

**វីក់**

**នៅក្នុងក្រអៅបេះដូងរបស់ម្តាយគឺជារណ្តៅមួយដែលជ្រៅនឹងពេញពោរដោយក្តីមេត្តាប្រោសប្រណី ។**

**ធារី**

វាមិនដូចមុនទេ…..
វាមិនដូចមុនទេ…..

| | |
|---|---|
| **ចំរៀងទុត្តា ” បទ សំណោកខ្លោចទួញ ”**<br>**និពន្ធដោយលោក អ៊ូ សំអើរ**<br><br>ឱ ស្នេហ៍អើយ !<br>នាងអន្ទោកអន្ទោលអោយបងវងសោកឥតស្រាក។<br>អំណឹះតទៅ ភពបង ផ្សេងហើយ។<br>អំណឹះតទៅចុងឈើជាស្ថានបងរហូតហើយ ។<br><br>ចាំស្តាប់សំណោកបងតាមខ្យល់ចុះ<br>មើលទុក្ខព្រួយបងតាមមេឃស្រទំ<br>ស្ទាបទឹកភ្នែកបងតាមរយៈទឹកភ្លៀងទៅ<br>ណា ស្នេហ៍សម្លាញ់ បង ! | |